# សិលាចារឹកសំស្ក្រឹតនៅប្រាសាទអំពិលរលំ K.162

នៅក្នុងឯកសារមុនៗដែលសិក្សាដោយអ្នកស្រាវជ្រាវជនជាតិបារាំង គេច្រើនហៅប្រាសាទនេះថា «អំពិលរលំ» ប៉ុន្តែឈ្មោះនេះសព្វថ្ងៃពុំមានអ្នកស្រុកណាម្នាក់ស្គាល់ឡើយ ព្រោះអ្នកស្រុកហៅតៗគ្នាថា «ប្រាសាទបី»។ ប្រាសាទបី មានទីតាំងស្ថិតនៅភូមិអណ្ដូងត្រុំ ឃុំចំណាលើ ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមានចម្ងាយប្រមាណ ៤០ គ.ម. ភាគពាយព្យទីរួមខេត្តកំពង់ធំ និងមានចម្ងាយប្រមាណ ១៨ គ.ម. ពីទីប្រជុំជនស្រុកស្ទោង។ ប្រាសាទបី សាងអំពីឥដ្ឋរាងបួនជ្រុងស្មើ មានតួប៉មបីរត់ជួរគ្នាពីជើងទៅត្បូង បែរមុខទៅទិសខាងកើត។[១] សព្វថ្ងៃតួប៉មកណ្ដាលនៅឈររូបរាង ក្បែរព្រះវិហារថ្មីមួយនៅខាងកើត រីឯតួប៉មសងខាងចំនួនពីរទៀតបានបាក់បែក និងបាត់រូបរាងទាំងស្រុងទៅហើយ។ រីឯប្រាសាទដែលនៅមានរូបរាងក៏មិននៅល្អពេកដែរ គឺផ្នែកដំបូលបានបាក់បែកទាំងស្រុងទៅហើយ (រូបលេខ១-២)។

សិលាចារឹក K.162 (រូបលេខ៣-៥) វិញ ចារឹកនៅលើមេទ្វារទាំងសងខាងនៃតួប៉មកណ្ដាលប្រាសាទអំពិលរលំ។ សិលាចារឹកនេះ ធ្លាប់មានរៀបរាប់នៅក្នុងសៀវភៅរបស់លោក Etienne Aymonier កាលពីឆ្នាំ១៩០០ តែមិនបានបរិយាយអ្វីច្រើននោះទេ ពោល គឺលោកគ្រាន់តែបញ្ជាក់ថាមានសិលាចារឹកនៅលើមេទ្វារតែប៉ុណ្ណោះ។[២] បន្ទាប់មកទៀត លោក Lunet De Lajonquière ក៏បានយោងសេចក្ដីប្រែរបស់លោក Etienne Aymonier ក្នុងសៀវភៅរបស់គាត់នៅពីរឆ្នាំបន្ទាត់ដូចគ្នា។[៣] ក្រោយមកទៀត នៅឆ្នាំ១៩៥៤ ទើបអ្នកប្រាជ្ញដ៏ល្បីឈ្មោះ George Coedès បានសិក្សាលម្អិតឡើងវិញក្នុងឆ្នាំ១៩៥៤។[៤]

សិលាចារឹកនេះ មានពីរផ្នែក គឺខាងជើងចារឹកជាភាសាសំស្ក្រឹតមានចំនួន ២២បន្ទាត់ ស្មើនឹង ១១ស្លោក និងផ្នែកខាងត្បូងវិញចារឹកជាភាសាសំស្ក្រឹតចំនួន ២៨បន្ទាត់ (ស្មើនឹង ៩ស្លោក និង៥បន្ទាត់ជាពាក្យរាយ) ហើយចារជាភាសាខ្មែរចំនួន ២ បន្ទាត់។ សិលាចារឹកនេះ ចារឹកឡើងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ (គ.ស.៩២៨-៩៤១) ប៉ុន្តែបានរំឭករឿងរ៉ាវអំពីមន្ត្រីនិងរជ្ជកាលស្ដេចអង្គមុនៗ ដូចជា ទ្រវិរ ដែលជាមន្ត្រីក្នុងរជ្ជកាលព្រះបាទស្រីយសោវរ្ម័ន ព្រះបាទហស៌វរ្ម័ន និងជា

[១] Lajonquière, 1902: 260.

[២] Aymonier, 1900: 442.

[៣] Lajonquière, 1902: 261.

[៤] Coedès, 1954: 100.

អត្ថបទដោយ៖ កំ វណ្ណារ៉ា

*អ្នកបានកសាងសម្មិទ្ធិផលបុណ្យនានាក្នុងទេវស្ថានប្រាសាទនេះ។ មេទ្វារខាងជើង មានចំនួន ២២ បន្ទាត់ ស្មើនឹង១១ស្លោក ចាររៀបរាប់អំពីព្រឹត្តិការណ៍ដើមស.វ.ទី៩ ស្តីពី "ពិធីទេវរាជរបស់ព្រះបាទជយវម្ម័នទី២ នៅលើភ្នំមហេន្ទ្រគិរី ដោយមានបញ្ជាក់ដល់ព្រាហ្មណ៍ "ហិរណ្យទាម" ត្រូវជារាជព្រាហ្មណ៍ដែលព្រះបាទបរមេស្វរ (ជយវរ្ម័នទី២) អញ្ជើញមកពីជនបទ ហើយគាត់ជាអ្នកប្រាជ្ញខាងសិទ្ធវិទ្យា មករៀបចំពិធីកម្រតេងជគត្តរាជ្យ និងបង្រៀនព្រាហ្មណ៍សិវកៃវល្យជាព្រះរាជគ្រូរបស់ព្រះបាទបរមេស្វរ។*

**អត្ថបទចារឹកដើម**

*មេទ្វារខាងជើង*

| | | |
|---|---|---|
| (១-៨) | ................................ | |
| ៩. | ...ហ្មន្យ អវិច្ចូត ............ក្រមមិ | |
| ១០. | .ន្ទ្រ..នរហូតក្វង្គ៌ | ............ត្រីយះ។ |
| ១១. | ចតុក៌ុជក្វជោ តីវ | ចតុម៌្មុខរជោក្និតតិ |
| ១២. | ចតុម៌្មខៅង្គ្ការជរតិ | ត្រី..ជ្យ..មតកង្គ្ការះ។ |
| ១៣. | ជាវិត្រិត្រីសរស្វត្យា | កុវឌត្រយកាយយា |
| ១៤. | ព្រហ្មេតវិម្លម្វត៌្យា.និ | ឥយំ ជាឲ្យុឌយតិ ត្រីយះ។ |
| ១៥. | .........ឥមំ ជីមានិ | យាប..ត សក្ខ្វជាជុនំ |
| ១៦. | ក្រហ្មវិម្ល្វីក្វរីភ្វតសិ | ស និភ៌្វណា ......។ |
| ១៧. | ..ចន្ទ្រក្វលតណិតេ | តាកោវ្ទ.ស ស្រ្តិ..ន្ទុ |
| ១៨. | បូម្យមាសាស្រ្តនិវសេ | កុក្ទេ វេ ...ភពតិ។ |
| ១៩. | ក្រាតា ហិរណ្យទាមស្យ | ធេវនិត្យ..ត្តមះ |
| ២០. | ហ្យុតាច្ច៌ណីក្វរភពតិ | ត...ន្ទ្យាត្មវិជាម្វរះ។ |
| ២១. | ជម្ម៌ានិត្យជិរាជេន្ទ្រតិ | ត្រីន្ទ្រានិត្យសុតស្យ ជះ |
| ២២. | រាជ្ជតិ ត្រីភពបុរេ ស្មិនិ | យជមាណីក្វរស្យ វិតិ។ |

*មេទ្វារខាងត្បូង*

| | | |
|---|---|---|
| ១. | ............................ | |
| ២. | ............ឌ ជាតា | ស្ថិត .................. |
| ៣. | ..........យុក្ត..... | ..ធ្យេ ...យោជ្យំ ...លះ។ |
| ៤. | ..................... | វិជាតា ភវិនិ វិភៅ |
| ៥. | ....................... | ជកនិ ធូតរជោត្ម ។ |

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

៦. ........................ .ត្នាន្តជវិជាយវេ

៧. ........................ កង្ក័រះ បង្ករេ ស្ដ ភះ។

៨. ........................ ..............................

៩. ........................ កង្ក័រះ កង្ក័ពេ ស្ដ ពះ។

១០. ........................ សតិ ត្រីកទ្រេក្វាហ្យំ

១១. ឥតិ ច្រាតិម្ពិបតិ ភក្ត្យា............ក្និមង្គលេ។

១២. អនិន្ទិតបុរេ វាសោ ..................ទ្វយេ

១៣. អក្វឌិ វិក្វតិ ក្វយិម្ពោ វសុទេវាភិជានជ្មតិ។

១៤. ការង្ក័ជារី ពង្កាព្វ កុណាភក្តិមហាត្តយា

១៥. វហុជា វហុ មេនេ យះ កាជីយានិ ឥវ ក្វក្មតា។

១៦. អត្រជីះ កម្ម៌សចិវះ កម្ម៌ព្យាចារចាជវាតិ

១៧. ត្រីយគោវម្ម៌ទេវេន នរទេវេន យះ ក្មតះ។

១៨. ត្រីហាប៌វម្ម៌ណោ ក្មត្យះ ត្រីយគោវម្ម៌វល្ភះ

១៩. សតិ ត្រីន្មបេន្ទ្រាវីពេ ជាចិ ជិវេ សៅពណ្ណ៌កោកតាំ។

២០. ភគវតតិ ត្រីយគោវម្ម៌ទេវេន្ទ្រាជិវាជតិ សុវាសុរមហាមិតនសំស្ត្វយមានចរ

២១. ចាធាវិន្ទមិ យស្យ វសុធោត្តរំ ភគវតតិ ត្រីត្រិបុរាន្តកោក្វរេ ជិតតិ។

២២. ពគវតតិ ត្រីជយវម្ម៌ទេវេន្ទ្រាជិវាជេន ត្រិកុពនស្ថាណាជីម្មិកោ

២៣. ន មហាន្តុតយតវិរិដេណាបរាក្រាមេន សហា ពកុរ យស្យ ពសុ

២៤. ធ្នូរ.........ភគវតតិ ត្រីត្រិបុរាន្តកោក្វរេ ភក្ត្យាជិតតិ។

២៥. ប្វជាចំ អស្យ យតិ វទ្ធំ ហេមារូប្យាជិកានិ ជនមិ

២៦. ហរន្តិយេ ន កិញ្ចិ ចិតិ តេ ពសន្តិ នរកេ ចិរំ។

២៧. ប្វជាចំ អស្យ យតិ វទ្ធំ ចាលយន្តេន តេ នរះ

២៨. សុកតឹ យាន្តិ ស្វកុលៃះ ស្វត្តំ យាន្តិ ចិរំ វសេតិ ។

២៩. ....គាសន ធ្វលីវ្រះចាន ធ្វលីជេង វ្រះកាម្រតេង អញ

៣០. ...សំ នុ រាជបុន្យ វ្ងំ ជា បិ ធារ វ្រហ៊ិ វ្ងំជាបិ ធារ បយ៉្យង

**បំណកប្រែ**

*មេឡារខាងដើង*

*(១-៨)* ................................

អត្ថបទដោយ៖ កំ វណ្ណារ៉ា

៥. អវិធូត មិនមានសេចក្តីសៅហ្មង គ្រឹយះ សិរីសួស្តី គ្ឍជ្ឈ៍ កំពូល ហូតបូជា នរ ដោយនរៈ ជន មានទេវេន្ទ្រជាដើម។

៦. គង្គះ ព្រះសង្ករៈ សម្តៅដល់ព្រះសិវៈ គ្រីជ្យោតិមត មានពន្លឺរស្មី ដ៏ត្រចះត្រចង់ ធរតិ ទ្រទ្រង់។

៧. គ្រឹយះ សិរីសួស្តីកើតពី ព្រះព្រហ្ម វិស្ណុ ជាឡុទយតិ (ជាតិ+ឧទយតិ) បើប្រែថាសព្វថា ព្រះអាទិតរះចេញពី ក្នុងអត្ថបទនេះប្រែថា កើតចេញពី ឥយំ ប្រែថា នេះ ព្រហ្មេតវិស្នុមូត្យាទ អំពី ព្រះ ព្រហ្ម និងព្រះវិស្ណុ កុវទត្រយកាយយា មានកាយជា ភពទាំង៣ គ្រឹសរស្វត្យា ព្រះនាង ស្រីសរស្វតិ។

៨. ស អង្គនោះ និរ្វាណ (បាលី និព្វាន) ភូតសិ កើតមាន, កើត ក្រហ្មវិប្វីគ្វរី ព្រះព្រហ្ម ព្រះ វិស្ណុ ព្រះឥសូរ។

៩. ក្នុងឆ្នាំសក គណនាដោយ គូល=៧ ចន្ទ្រ=១ .... ទី៨កើត ខែបុស្ស ....។

១០.បងប្រុស នៃហិរណ្យទាម, ទេវទិត្យ ប្រសើរខ្ពង់ខ្ពស់ .......ជាអ្នកមានអាត្មន៍ដ៏បរិសុទ្ធ... ស្វាមី

បានបូជាតង្វាយដល់ព្រះអគ្និ។

១១. ព្រះមហាក្សត្រនៃក្រុងស្រីកពបុរ (ស្រីកវបុរ) និងរាជបុត្រមានថា ស្រីឥន្ទ្រាទិត្យ, រាជសេវកាមាត្យ(មន្ត្រី) របស់ព្រះរាជានាម ធម្មាទិត្យ បានថ្វាយតង្វាយក្នុងទេវស្ថាននេះ។

**មេទ្វារខាងត្បូង**

១. ដោយចំពោះស្លោកទី១ នេះរលុបបាត់ពាក្យជាច្រើននៅសេសសល់តែពាក្យមួយចំនួន ដូចជា យុក្ត ប្រែថាប្រកប, ស្ថិត ប្រែថាស្ថិត តាំងនៅ, តម្កល់ ជាតាប្រែថា បង្កើត, ប្រភពដើម , កំណើត ថែ

រក្សា,អ្នកផ្តើម,អ្នកគាំពារ។ ដូច្នេះអត្ថបទនេះ ជាប្រភេទ ពាក្យបួងសួងសូមប្រទានពរ ពីទេពជាម្ចាស់។

២. (ស្លោកនេះរលុបបាត់ បាទទី១ និងបាទ៣ ទាំងស្រុង សល់តែបាទទី២ និងបាទទី៤ ប៉ុណ្ណោះ យោងតាមពាក្យសេសសល់ អត្ថបទនេះជាពាក្យបួស ឬពាក្យគោរពនមស្ការបូជាដល់ ទេពជាម្ចាស់អ្នកបង្កើតលោក)។

អត្ថបទដោយ៖ កំ វណ្ណាវ៉ា

៣. (ស្លោកនេះរលុបបាត់ បាទទី១ និងបាទ៣ ទាំងស្រុង សល់តែបាទទី២ និងបាទទី៤ ប៉ុណ្ណោះ យោងតាមពាក្យសេសសល់ អត្ថបទនេះជាពាក្យបួស ឬពាក្យគោរពនមស្ការបូជាដល់ ព្រះសង្ករទេព បុស្ករទេព។

៤. ស្លោកទី៤ នេះ រលុបអស់ សល់តែនាម ព្រះគេឧទ្ទិសដល់ ពោលគឺព្រះសង្ករ (ជាព្រះនាមព្រះសិវៈ ខ្មែរច្រើនប្រើភ្ជាប់ថា សង្ករនារាយណ មានន័យថា ព្រះសង្ករ=សិវៈ និងព្រះនារាយណ=វិស្ណុ)។

៥........ប្រតិស្ថាន ទេពមាននាមថា ស្រីកច្រេស្វរ ដោយសេចក្តីគោរព ក្នុងឆ្នាំនៃសក. កំណត់ដោយ មង្គល=៨ អគ្និ៣ និង......។

៦. នៅក្នុងក្នុងទីក្រុង អនិន្ទិតបុរ .............មានទេវស្ថានមួយ មាននាមថា វសុទេវ (វសុទេព) បរិបូណ៌ដោយភោគទ្រព្យសម្បត្តិ។

៧. ករង្កធារី ពង្កាត្ត គុណាភក្តិមហត្តយា
វហុធា វហុ មេនេ យះ កទីយានិ ឥវ ភូក្ភូតា។

៨. ព្រោះតែ បាដវ ឈ្លាសវៃ កម៌វ្យាបារ ឈ្លាសក្នុងការងារ អគ្រនីះ ខ្លាំងខ្លា កម៌សចិវះ ការងារល្អ ដោយភាពឆ្លាតវៀងវៃ ចំណេះដឹង សកម្មភាព គាត់ត្រូវបានតែងតាំងជា មន្ត្រីជាន់ខ្ពស់ ដោយព្រះបាទ ស្រីយសោវម៌្មនទេវៈ។

៩. រាជសេវកាមាត្យ (មន្ត្រី)របស់ព្រះបាទ ស្រីហស៌វម៌្មន ជាទីរាជប្រីយ៍ (ជំនិតឬទីពេញចិត្ត) របស់ព្រះបាទស្រីយសោវម៌្មន នាមស្រីន្ទ្របេន្ទ្រវីរ បានថ្វាយ សៅវណ៌្ណកោស ដល់ព្រះសិវៈ។

ក្នុងអត្ថបទពាក្យចារឹកនេះ បន្ទាត់ទី១០ ដល់បន្ទាត់ទី១៤ ចារឹកជាពាក្យរាយធម្មតា៖

(១០-១១). ព្រះបាទស្រីយសោវម៌្មទេវ ជាស្តេចអធិរាជ ចរបាទារវិន្ទម៑ ទ្រង់មានព្រះស្រីវរបាទទ្រដោយ កមលជាតិ(ផ្កាឈូក) សំស្ងួយមានទ្រង់ទទួលបានការគោរពបូជា អំពី គន (គណ) មហាជន ឬប្រជាជន សុរ ពួកសុរៈ អសុរ ពួកអសុរៈ មហចំ្សិ ពួកមហាសិ៎ យស្ស នៃព្រះរាជា វសុធោត្តរំ សម្រាប់ការទ្រទ្រង់ ប្រទានដ៏ប្រសើ (ទ្រទ្រង់ផែនដី) បើប្រែសម្រួលថា រាជតង្វាយរបស់ព្រះបាទស្រីយសោវម៌្មទេវ កគវតគ៌ គ្រីត្រិបុរាន្តកេគ្វរ ថ្វាយសម្រាប់ព្រះ ស្រីត្រិបុរាន្តកេស្វរ។

(១២-១៤). ព្រះបាទស្រីជយវម៌្មទេវ ព្រះអង្គជាស្តេច អធិរាជ ដែលទទួលបានការប្រទានពរថា ទ្រង់ជា ស្តេចបរាក្រម (ខ្លាំងពូកែ,មិនដែលបរាជ័យ) ដោយប្រការៈផ្សេងៗ មាន មានយសធំដូចជាអ្នកបង្កើតនូវ ត្រៃភព សហ រួមជាមួយ ពភុវ មាន យស្ស នៃព្រះរាជា ពសុន្ធរ[ណោទ] គឺ

អត្ថបទដោយ៖ កំ វណ្ណារ៉ា

សម្រាប់ទ្រង់ ឬផ្តត់ផ្តង់ ភគវតគ៏ ត្រីត្រិបុរាន្តកេត្វរ ភក្ត្យា ទិគត៌ ក្នុង ព្រះភគវត៌ ស្រីត្រិបុរាន្តស្វរ ដោយសេចក្តីគោរព។

១៥. ជនទាំងឡាយណា យកទ្រព្យសម្បត្តិទាំងឡាយ មាន មាស ប្រាក់ជាដើម ដែលបាន បូជាថ្វាយដល់ទេពក្នុងស្ថានទីនេះ ជននោះធ្លាក់ក្នុងស្ថាននរកអស់កាលជាយូរអង្វែង។

១៦. នរៈជនណា បានជួយថែរក្សាទ្រព្យសម្បត្តិ ដែលបានបូជាថ្វាយដល់ទេវស្ថានក្នុងទីស្ថាននេះ នរៈជននោះ និងទៅកាន់ស្ថានសួគ៌ សុគតិទេវលោក អស់កាលជាយូរអង្វែងរួមជាមួយ នឹងវង្សត្រកូលក្រុមគ្រួសារ។

តាមរយៈអត្ថន័យសិលាចារឹកនេះ យើងបានដឹងច្រើនទាក់ទងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ។ ក្នុងនោះ សិលាចារឹកនៅមេទ្វារខាងជើង បានចាររៀបរាប់រំឭកពីរឿងរ៉ាវនៅដើមស.វ.ទី៩ ស្តីអំពីពិធី ទេវរាជរបស់ព្រះបាទជយវរ្ម័នទី២ នៅលើភ្នំមហេន្ទ្រគិរី (ភ្នំគូលែន) ដោយមានបញ្ជាក់ដល់ព្រាហ្មណ៍ ហិរណ្យទាម ជារាជព្រាហ្មណ៍ ដែលព្រះបាទបរមេស្វរ[៥] (ជ័យវរ្ម័នទី២) អញ្ជើញមកពីជនបទ គាត់ជាអ្នកប្រាជ្ញខាងសិទ្ធវិទ្យា មករៀបចំពិធីកម្រតេងជគតតរាជ និងបង្រៀនព្រាហ្មណ៍ សិវកៃវល្យ ដែលជារាជគ្រូរបស់ព្រះបាទបរមេស្វរ។

ក្នុងសិលាចារឹកនៅមេទ្វារខាងជើងនេះ បានរំលេចនូវពាក្យមួយគឺ “**កម្រតេងជគតតរាជ**” ដែលពាក្យនេះ គេក៏បានប្រទះឃើញនូវសិលាចារឹកស្តុកកក់ធំនាសតវត្សរ៍ទី១១ ហើយរំឭកពីរឿងរ៉ាវនាដើមសតវត្សរ៍ទី៩ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ដូចគ្នា។[៦] ប្រវត្តិវិទូជាច្រើន បានផ្តោតការយកចិត្តទុកដាក់តែលើផ្នែកភាសាសំស្រ្កឹតនៃសិលាចារឹកស្តុកកក់ធំ ហើយបានបកស្រាយថា «ទេវរាជ» គឺស្តេចដែលជាទេព (ទេវរាជ) ឬស្តេចនៃទេពទាំងឡាយ។ លោក Goerge Coedès ក៏បាន គិតដែរថា «ទេវរាជ» គឺជាប្រភេទសីវលិង្គម្យ៉ាងតំណាងឱ្យស្តេច ហើយស្តេចគ្រប់អង្គដែលគ្រងរាជ្យបន្ទាប់ពីព្រះបាទជ័យវរ្ម័នទី២ បានស្ថាបនាប្រាសាទមួយកណ្តាលទីក្រុងដើម្បីឧទ្ទិសចំពោះ

---

[៥]បរមេស្វរ គឺជាឈ្មោះមរណៈនាមរបស់ព្រះបាទជ័យវរ្ម័នទី២។ ជាទូទៅ ព្រះមហាក្សត្រនៅសម័យអង្គរ មានព្រះនាមចំនួនបី ពោល គឺមុនពេលឡើងសោយរាជ្យមានព្រះនាមមួយ, ពេលសោយរាជ្យមានព្រះនាមមួយ និងពេលសោយទិវង្គតមានព្រះនាមមួយទៀត។ ឧទាហរណ៍៖ ព្រះបាទជ័យវរ្ម័នទី៣ ដែលត្រូវជាបុត្រាព្រះបាទជ័យវរ្ម័នទី២ នៅមុនពេលឡើយសោយរាជ្យមានព្រះនាមថា "ជ័យវទ្ធន", លុះពេលទ្រង់សោយទិវង្គតទៅ មានព្រះនាមថា "វិស្ណុលោក"។

[៦]គប្បីចាំថា អ្នកប្រវត្តិវិទូអឺរ៉ុប ដែលបានសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរដំបូងៗក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ ពុំសូវយកភស្តុតាងណាបញ្ជាក់អំពីព្រឹត្តិការណ៍របស់ទ្រង់ក្រៅអំពីសិលាចារឹកដែលចារក្រោយរឿងរ៉ាវ ២ ឬ ៣សតវត្សរ៍នោះទេ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

ទេវរាជ។ ប៉ុន្តែបើពិនិត្យមើលទៅលើផ្នែកភាសាខ្មែរនៃសិលាចារឹកស្តុកកក់ធំវិញ ការពន្យល់របស់គេផ្សេងពីនោះ។ ឈ្មោះជាភាសាខ្មែរ "កម្រង់តេង៑ ជគត ត រាជ" ពុំមានទំនាក់ទំនងចំពោះព្រះឥសូរទេ។ ពាក្យនោះ មានន័យថា "កម្រតេង៑" ប្រែថា "ជាម្ចាស់", "ជគត" ជាពាក្យសំស្ក្រឹតប្រែថា "ពិភពលោក", "ត" ប្រែថា "ន័យ", "រាជ" ប្រែថា "ស្តេច"។ ចំណែក ការពន្យល់របស់លោក Claude Jacques វិញ គាត់បានបង្ហាញថា "កម្រតេង៑ ជគត ត រាជ" គឺជាទេពការពារស្រុកម្យ៉ាងរបស់ខ្មែរដូចជា អ្នកតា មានអំណាចខ្លាំង ហើយមានកម្រេង់តេង៑ជគតតរាជ លើសពីមួយក្នុងពេលតែមួយ។ សំណួរមួយគឺ តើហេតុអ្វីបានជាខ្មែរយកពាក្យសំស្ក្រឹត "ជគត" មកប្រើ? លោក Michael Vickery បានពន្យល់ថា ខ្មែរបុរាណពុំមានពាក្យសម្រាប់ពិភពលោកទាំងមូល ឬសូម្បីពាក្យសម្រាប់អាណាចក្រធំមួយដែលកើតមកពីការរួមបញ្ចូលអាណាចក្រតូចៗជាច្រើនៗ ឬរដ្ឋតូចៗ។ ពាក្យខ្មែរតែមួយគត់ដែលគេប្រើគឺ "ស្រុក" ដែលជាទឹកដីមួយតូច ហើយមានន័យថាជាដីសម្រាប់ស្តេចត្រាញ់ ឬ  បោញគ្រប់គ្រង។ ដូច្នេះពាក្យនេះ ពុំសក្តិសមនឹងទេពពិសេសសម្រាប់ស្តេចអស្ចារ្យដូចស្តេចអង្គរទេ។[៧]

ចំណែក ស្លោកទី១១ នៃសិលាចារឹកប្រាសាទអំពិលរលំ K.162 មេទ្វារខាងជើង បានបង្ហាញឱ្យយើងស្គាល់អំពីព្រះមហាក្សត្រមួយអង្គដែលសោយរាជ្យនៅ "**ក្រុងស្រីភពបុរ**" (ស្រីភវបុរ), មានរាជបុត្រព្រះនាមថា "**ស្រីឥន្ទ្រាទិត្យ**", រាជសេវកាមាត្យ (មន្ត្រី) របស់ព្រះរាជានាម "**ធម្មាទិត្យ**" បានថ្វាយតង្វាយក្នុងទេវស្ថាននេះ។ ក្នុងស្លោកនេះ យើងចង់បង្ហាញខ្លះៗអំពីទីតាំងនៃក្រុង "ស្រីភពបុរ" ឬអក្សរតាមបែបសំស្ក្រឹតថា "ស្រីភវបុរ" ថានៅទីណានៃស្រុកខ្មែរបច្ចុប្បន្ន?

ប្រវត្តិវិទូទាំងឡាយ មានគំនិតខុសៗគ្នាអំពីភវបុរ។ ក្នុងសៀវភៅរបស់លោក Goerge Coedès ដែលមានចំណងជើងថា "The Indianized States" នៅឆ្នាំ១៩៤៨ និងក្នុងការសរសេររបស់លោក Pirre Dupont និយាយថា ភវបុរ នៅខាងជើងវត្តភូ និងខាងជើងភ្នំដងរែក គឺស្ថិតនៅភាគខាងត្បូងឡាវ និងភាគឦសានទឹកដីថៃ។ ដ្បិតគេគិតថាឈ្មោះ "ភវបុរ" គឺសំដៅលើព្រះបាទភវវរ្ម័ន ទី១ ហើយពួកគាត់ជឿទៀតថាព្រះបាទភវវរ្ម័នទី១ ជាស្តេចចេនឡាដែលស្ថិតនៅភាគខាងជើងឆ្ងាយ មុនពេលចេនឡាឈ្លានពានហ្វូណន។ មុនដំបូងពួកគាត់ក៏គិតដែរថា ភវបុរ គឺនៅឆ្ងាយពីអង្គរជារដ្ឋឯករាជ្យមួយ រហូតដល់រជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស.៩៤៤ ដល់ ៩៦៨) ដែលជាស្តេចភវបុរបានបង្រួបបង្រួមភវបុរជាមួយអង្គរ។ ឥឡូវលោក Claude Jacques គិតថា "ភវបុរ" ជា

[៧]Michael Vickery (2006-2007): *"History of Cambodia"*, p.56-57, Summary of lectures given at the Faculty of Archaeology of Fine Arts, Vidya Series, Pre-Angkor Studies Society, Phnom Penh.

*ឈ្មោះសំបូរព្រៃគុក ប៉ុន្តែគាត់នៅតែគិតថាទីនោះគឺជារដ្ឋឯករាជ្យមួយរហូតដល់រាជ្យព្រះបាទរាជេន្ទ្រវរ្ម័ន។ លោក* Michael Vickery *បានយល់ស្របគំនិតរបស់លោក* Claude Jacques *ដែលថាសំបូរព្រៃគុកមានឈ្មោះថា "ភវបុរ" ក្នុងរាជ្យបុត្រារបស់ព្រះបាទឦសានវរ្ម័នទី១ គឺព្រះបាទភវវរ្ម័នទី២ និងក្រោយពេលកន្លែងនោះមានឈ្មោះថា "ឦសានបុរ" ក្នុងរាជ្យព្រះបាទឦសានវរ្ម័នទី១។ លុះក្រោយមក នៅពេលដែលលោក* Goerge Coedès *បានរកឃើញសិលាចារឹកអំពិលរលំនេះ លោកបានប្តូរគំនិតដោយគាត់លែងគិតថា ភវបុរ នៅឡាវទៀតហើយ ផ្ទុយទៅវិញគាត់យល់ថា "ភវបុរ" ទំនងនៅម្តុំអំពិលរលំនេះតែម្តង។*[៨] *ទាំងនេះគឺគ្រាន់តែជាការយល់ផ្សេងៗពីគ្នារបស់អ្នកប្រវត្តិវិទូ ប៉ុន្តែចម្ងល់ដែរថា តើភវបុរនៅទីណាពិតប្រាកដនោះ ពុំទាន់បានបកស្រាយនៅឡើយទេ។*

*ដោយឡែក នៅក្នុងសិលាចារឹកប្រាសាទនេះនៅមេទ្វារខាងត្បូងវិញ ក៏បានឱ្យយើងយល់អំពីរឿងរ៉ាវប្រវត្តិសាស្ត្រជាច្រើនចាប់ពីរជ្ជកាលព្រះបាទយសោវរ្ម័នទី១* (គ.ស.៨៨៩-៩១០) *ព្រះបាទហស៌វរ្ម័នទី១* (គ.ស.៩១០-៩២១) *និងព្រះបាទជ័យវរ្ម័នទី៤* (គ.ស.៩២៨-៩៤១)*។ ស្តេចទាំងអម្បាលម៉ាននេះ បានធ្វើតង្វាយដល់ព្រះអាទិទេពនិកាយព្រះឥសូរតម្កល់នូវទេវស្ថាននេះព្រះនាម* ***«ស្រីត្រិបុរាន្តកេស្វរ»*** *។ នៅស្លោកទី១០-១១ នៃសិលាចារឹកនេះ បានរៀបរាប់ពីភាពអស្ចារ្យនៃព្រះបាទស្រីយសោវម្ម័ទេវ ថាទ្រង់គឺជាស្តេចអធិរាជ* ***ចរបាទារវិន្ទមិ*** *ទ្រង់មានព្រះស្រីរបាទទ្រដោយកមលជាតិ* (ផ្កាឈូក) *សំស្តួយមានទ្រង់ទទួលបានការគោរពបូជា អំពី គន* (គណ) *មហាជន ឬប្រជាជន។ ចំណែក ស្លោកទី១២-១៤ ក័បានរៀបរាប់អំពីភាពអស្ចារ្យរបស់ព្រះបាទស្រីជយវម្ម័ទេវ ដូចគ្នា គឺពោលសរសើរដល់ព្រះអង្គថា ជា ស្តេចអធិរាជ ដែលទទួលបានការប្រទានពរថា ទ្រង់ជា* ***ស្តេចបរាក្រម*** (ខ្លាំងពូកែ,មិនដែលបរាជ័យ) *ដោយប្រការៈផ្សេងៗ មាន មានយសធំ ដូចជាអ្នកបង្កើតនូវ ត្រៃភព សហ រួមជាមួយ ពក្ស មាន យស្ស នៃព្រះរាជា។ ជាពិសេសនោះ គឺបន្ទាត់ទី១៥ ដែលចារឹកជាភាសាខ្មែរ បានឱ្យយើងដឹងអំពីការដាក់បណ្តាសានាសម័យបុរាណចំពោះជនណាដែលបំផ្លាញសម្បត្តិនៅទេវស្ថាន "ជនទាំងឡាយណា យកទ្រព្យសម្បត្តិទាំងឡាយ មាន មាសប្រាក់ជាដើម ដែលបានបូជាថ្វាយដល់ទេពក្នុងស្ថានទីនេះ ជននោះធ្លាក់ក្នុងស្ថាននរកអស់កាលជាយូរអង្វែង" ហើយបន្ទាត់ទី១៦វិញ បានឱ្យយើងយល់អំពីការប្រទានពរសម្រាប់ជនណាដែលថែរក្សាសម្បត្តិនៅទេវស្ថាន «នរៈជនណា បានជួយថែរក្សាទ្រព្យសម្បត្តិ ដែលបានបូជាថ្វាយដល់*

---

[៨] Michael Vickery (2006-2007): *"History of Cambodia"*, p.72-74, Summary of lectures given at the Faculty of Archaeology of Fine Arts, Vidya Series, Pre-Angkor Studies Society, Phnom Penh.

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

*ទេវស្ថានក្នុងទីស្ថាននេះ នរៈជននោះ និងទៅកាន់ស្ថានសួគ៌ សុគតិទេវលោក អស់កាលជាយូរ អង្វែងរួមជាមួយនឹងវង្សត្រកូលក្រុមគ្រួសារ»។*

ជារួមមក សិលាចារឹកសំស្ក្រឹតនៅប្រាសាទអំពិលរលំ K.162 ដែលចារឹកឡើងនៅសតវត្សរ៍ទី១០ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ បានឱ្យយើងយល់ដឹងអំពីរឿងរ៉ាវជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រ រួមមាន ព្រឹត្តិការណ៍នាដើមសតវត្សរ៍ទី៩ ការប្រោះព្រួលពិធីទេវរាជ ការសរសើរអំពីអនុភាពនៃព្រះរាជា ស្គាល់ពីព្រះនាមព្រះមហាក្សត្រ ស្គាល់អំពីមន្ត្រីសំខាន់ៗ ស្គាល់អំពីឈ្មោះ ទីក្រុងសំខាន់ៗនៅរវាង សតវត្សរ៍ទី៩ដល់ស.វ.ទី១០ និងព្រមទាំងដឹងអំពីការដាក់បណ្ដាសានិងការប្រទានពរផងដែរ៕

## ឯកសារយោង


**Aymonier, Etienne**

1900, *“Le Cambodge”*, *Tome I, Le royume actuel*, Paris.

**Coedès, George**

1954, *Inscription du Cambodge*, Vol VI, Hanoi.

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris.

**Vickery, Michael**

2000 - 2001, *Summary of lectures given at the Faculty of Archaeology, Royal University of Fine Arts*, Phnom Penh.


អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ១១៖ ប្រាសាទអំពិលរលំ មើលពីមុខខាងកើត (រូបថត៖ ម៉ង់ វ៉ាលី)



រូបលេខ១២៖ ប្រាសាទអំពិលរលំ មើលពីមុខខាងត្បូង (រូបថត៖ ម៉ង់ វ៉ាលី)

អត្ថបទដោយ៖ កំ វណ្ណាព៉



រូបលេខ៣៖ ក្រដាសផ្តិតសិលាចារឹកសំស្ក្រឹតនៅប្រាសាទអំពិលរលំ (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៤៖ ក្រដាសផ្តិតសិលាចារឹកសំស្ក្រឹតនៅប្រាសាទអំពិលរលំ (ផ្តិតដោយ៖ កំ វណ្ណាក់)

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ៥៖ ក្រដាសផ្តិតសិលាចារឹកសំស្ក្រឹតនៅប្រាសាទអំពិលរលំ (ផ្តិតដោយ៖ កំ វណ្ណារ៉ា)